**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**
**អគ្គលេខាធិការដ្ឋាន**
លេខ: ០៤៦/១៨ អ.ជ.ប.គ.ញ

ថ្ងៃព្រហស្បតិ៍ ៣កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨

# របាយការណ៍
## ស្តីពី
## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែមេសា និងទិសដៅការងារ ខែឧសភា ឆ្នាំ២០១៨

(២៦/០៣/២០១៨ - ២៥/០៤/២០១៨)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, ការចូលរួមអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ក៏ដូចជាផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា - ៣១ ខែធ្នូ ឆ្នាំ២០១៨) របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមីនាកន្លងទៅ យើងបានកត់សម្គាល់ពីសភាពការណ៍គ្រឿងញៀន និងអនុវត្តការងារនៅក្នុងខែមេសានេះ ទទួលបានលទ្ធផលដូចតទៅ ៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែមេសានេះ កត់សម្គាល់ឃើញសកម្មភាពចរាចរ ដឹកជញ្ជូនគ្រឿងញៀនខុសច្បាប់ ដោយក្រុមឧក្រិដ្ឋជនពីតំបន់ត្រីកោណមាសឆ្លងកាត់ប្រទេសឡាវចូលមកកម្ពុជា តាមបណ្តាច្រកនៃខេត្តភាគឦសានប្រទេស បានកើតមាន ៤ ករណីធំៗ ក្នុងនោះ កម្លាំងមន្ទីរប្រឆាំងគ្រឿងញៀន បង្ក្រាប ៣ ករណី និងស្នងការដ្ឋាននគរបាល ខេត្តបន្ទាយមានជ័យ បង្ក្រាប ១ ករណី សរុបចាប់យកមេតំហ្វេតាមីន ICE - WY ជាង ២០ គីឡូក្រាម និងឃាត់ខ្លួនជនសង្ស័យជាជនបរទេស ២ នាក់ (កោះតៃវ៉ាន់) ។

ជាមួយនេះ ក៏មានការដឹកជញ្ជូនតាមបញ្ញើហ័ស និងប៉ុស្តិ៍ប្រៃសណីយ៍បានកើតឡើង ២ ករណី ផងដែរ ៖

- ករណីទី១ ផ្ញើពីប្រទេសប៉េរ៉ូ ឆ្លងកាត់ប៉ាណាម៉ា ហូឡង់ ខាងចុះប្រទេសចិន រួចចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិសៀមរាប រួចបន្តតាមផ្លូវគោកទៅប្រទេសថៃ តាមរយៈកញ្ចប់បញ្ញើហ័សរបស់ក្រុមហ៊ុន DHL ប៉ុន្តែត្រូវបានសមត្ថកិច្ចបង្ក្រាបទាន់ពេលវេលាដោយ ឃាត់ខ្លួនជនសង្ស័យជនជាតិថៃ ១នាក់ ។
- ករណីទី២ ផ្ញើពីប្រទេសហូឡង់ និងប្រទេសប៊ែលហ្សិក តាមរយៈកញ្ចប់បញ្ញើប្រៃសណីយ៍ ប៉ុន្តែត្រូវសមត្ថកិច្ចឃាត់ខ្លួនជនសង្ស័យជនជាតិបារាំង ១នាក់ ដែលជាអ្នកទទួលកញ្ចប់បញ្ញើ ។

សរុប២ករណីខាងលើ សមត្ថកិច្ចបានធ្វើការដកហូត កូកាអ៊ីន អ៊ិចស្តាស៊ី ប្រមាណជាង៣គីឡូក្រាម ។

ការកត់សម្គាល់នៅក្នុង ៦ ករណីធំៗខាងលើ សមត្ថកិច្ចបានចាប់យកមេតំហ្វេតាមីន ICE - WY ដល់ទៅ ៩៤% នៃការប៉ាន់ប្រមាណចំនួនមេតំហ្វេតាមីនក្នុងខែមេសានេះ ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529 P.O.Box: 151
E-mail: info@nacd.gov.kh Website : www.nacd.gov.kh

## II. អំពីការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី** ប្រធាន អ.ជ.ប.គ.ញ. បានបន្តដឹកនាំ និងណែនាំលើការងារសំខាន់ៗ ជាពិសេសការងារពាក់ព័ន្ធនឹងការអនុវត្តផែនការជាតិ ៣ ឆ្នាំ (២០១៦-២០១៨) ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងការចូលរួមអនុវត្ត ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ឆ្នាំ២០១៨ ដូចខាងក្រោម ៖

**១. ការងារអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន ៖** ត្រូវបន្តជំរុញការអនុវត្តវិធានការផ្សព្វផ្សាយអប់រំ ដល់សិស្ស-និស្សិត កម្មករ-ពលករ ជនចំណាកស្រុក តាមគ្រប់រូបភាព (ការផ្សព្វផ្សាយតាមបណ្តាញព័ត៌មាន ប្រព័ន្ធទូរស័ព្ទ ការបិទតាំងខ្លឹមសារអប់រំតាមគោលដៅទេសចរណ៍) និងការរៀបចំវេទិកាតុមូល វេទិកាសាធារណៈ វេទិកាជួបជាមួយវិស័យឯកជន ព្រមទាំងសកម្មភាពពាក់ព័ន្ធផ្សេងៗទៀត ។

**២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងការចាកចេញពីគ្រឿងញៀន ៖** ត្រូវបន្តពង្រឹងសមត្ថភាពមណ្ឌលបណ្តោះអាសន្នរដ្ឋនិងឯកជនឱ្យមាននិរន្តរភាព ដើម្បីទទួលជនរងគ្រោះដែលអង្គភាពអនុវត្តន៍ច្បាប់ ស្ថាប័នតុលាការបញ្ជូនទៅទទួលសេវាព្យាបាល, ត្រូវពង្រឹង ពង្រីកសេវាព្យាបាលដោយផ្អែកលើសហគមន៍តាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកបន្ថែមទៀត ។ ជាមួយនេះ ត្រូវពិនិត្យស្នើសុំមូលនិធិសមធម៌ដល់អ្នកញៀនគ្រឿងញៀន ឱ្យបានទទួលសេវាពិនិត្យ និងព្យាបាលភាពញៀនគ្រឿងញៀន ដោយឥតគិតថ្លៃនៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ ព្រមទាំងពង្រឹងសេវាគាំទ្រផ្សេងៗទៀត សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃការធ្វើសមាហរណកម្មទៅក្នុងគ្រួសារ និងសហគមន៍ ដើម្បីកាត់បន្ថយការលាប់ទៅប្រើគ្រឿងញៀនឡើងវិញ និងសូមបន្តការងារសាងសង់មណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍នៅភូមិឬទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ឲ្យបានឆាប់រហ័ស។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់ ៖** ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមរយៈការបណ្តុះបណ្តាលជំនាញត្រួតពិនិត្យគ្រឿងញៀន និងសារធាតុគីមីផ្សំ តាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ **(CBT)**, តាមប្រព័ន្ធអេឡិចត្រូនិក (e-Learning), និងការបណ្តុះបណ្តាលជំនាញផ្សេងៗទៀតដល់មន្ត្រីការិយាល័យទំនាក់ទំនងព្រំដែន **(BLO)**, មន្ត្រីអនុវត្តន៍ច្បាប់គ្រប់ប្រភេទទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្រុមជនបង្គោលនៃកងយោធពលខេមរភូមិន្ទ ។ ទន្ទឹមនេះ ត្រូវពន្លឿននីតិវិធីក្នុងការជម្រះក្តីពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ជាពិសេស រឿងក្តីដែលពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិឱ្យបានឆាប់ ដើម្បីគណៈកម្មការ ការតាមដាន ការប្រមូល ការគ្រប់គ្រង និងការចាត់ចែងទ្រព្យសម្បត្តិ បន្តនីតិវិធីហិរញ្ញវត្ថុ ឱ្យទាន់ពេលវេលា ចៀសវាងការខូចខាត ធ្លាក់ចុះតម្លៃ ឬឈានដល់បាត់បង់តម្លៃទាំងស្រុងនៃទ្រព្យសម្បត្តិទាំងនោះ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ ៖** បន្តជំរុញឲ្យដំណើរការក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យ សារធាតុគីមីផ្សំឱ្យបានទៀងទាត់ និងត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។ ជាមួយនេះ ត្រូវសហការជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម បន្តការរៀបចំសេចក្តីព្រាង បទប្បញ្ញត្តិស្តីពីការបិទ ស្លាកសញ្ញាការទុកដាក់ការវេចខ្ចប់នូវសារធាតុគីមីក្នុងវិស័យឧស្សាហកម្ម ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន ៖** បន្តអនុវត្តនូវរាល់កិច្ចការ ដែលបានព្រមព្រៀងគ្នាកន្លងមកជាមួយភាគីថៃ ឡាវ និង វៀតណាម ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនព្រមទាំងការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់ប្រទេសកម្ពុជា ថៃ និងឡាវ ជាពិសេសការរៀបចំភូមិ ស គ្មានគ្រឿងញៀន នៅតាមព្រំដែនដែលភាគីកម្ពុជា ឡាវ ថៃ បានឯកភាពគ្នាកន្លងមក ដោយមានកិច្ចអន្តរាគមន៍នានាដែលមានលក្ខណៈពហុវិស័យ ដើម្បីធ្វើជាបទពិសោធន៍ ក្នុងការពង្រឹង ពង្រីកការិយាល័យ

ទំនាក់ទំនងព្រំដែន **(BLO)** ចំនួន៥កន្លែង តាមបណ្តោយព្រំដែន កម្ពុជា-ឡាវ, កម្ពុជា-ថៃ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា ៖** បន្តអនុវត្តខ្លឹមសារនៃកិច្ចព្រមព្រៀងនានាទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី អង្គការ **UNODC** បណ្តាប្រទេសក្នុងអនុតំបន់ តំបន់ អន្តរជាតិ ការអនុវត្តគម្រោងសុវត្ថិភាពទន្លេមេគង្គ (Safe Mekong Project) ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៖** ត្រូវបន្តការកែសម្រួលមាត្រាមួយចំនួននៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិ ដែលជាផលបានមកពីបទល្មើសគ្រឿងញៀន និងបន្តស្នើសុំពិនិត្យនិងសម្រេចលើសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ជាមួយនេះ ត្រូវធ្វើការណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាព សម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

ក្រៅពីការងារដឹកនាំ និងណែនាំខាងលើ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានជួបសំណេះសំណាលនិងបញ្ជ្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀន ដល់មន្ត្រីរាជការ និងប្រជាពលរដ្ឋ នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ចំនួន ៤.៧២៨ នាក់ ។

## III. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

ឆ្លើយតបទៅនឹងទិសដៅការងារដែលបានដាក់ចេញកាលពីខែមីនា ឆ្នាំ២០១៨ និងតាមការណែនាំរបស់ **ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.** អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានបន្តអនុវត្តការងារទទួលលទ្ធផលដូចខាងក្រោម ៖

### ១. ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

#### ១.១. ការងារអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

- សហការជាមួយស្ថានីយទូរទស្សន៍ NICETV អញ្ជើញតំណាងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តបាត់ដំបង និងខេត្តកំពង់ចាម ធ្វើជាវាគ្មិនក្នុងកម្មវិធីដំណឹងមុនគេ ( First Talk Show ) ក្រោមប្រធានបទស្ថានភាព និងការបង្ការ បង្ក្រាបគ្រឿងញៀន
- សហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុក ជាអគ្គនាយក នៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុនៃធនាគារជាតិនៃកម្ពុជា ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣ ឆ្នាំ២០១៨
- តាមរយៈគេហទំព័ររបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (www.nacd.gov.kh) ក្នុងខែមេសា ឆ្នាំ២០១៨ មានការចូលអានចំនួន **៥៤.១៩៤ ដង**
- ផ្សព្វផ្សាយឃ្លីបវីដេអូខ្លីស្តីពីបញ្ហាគ្រឿងញៀន និងការគោរពច្បាប់ចរាចរណ៍ផ្លូវគោក តាមបណ្តាញទំនាក់ទំនងសង្គម Facebook ។

#### ១.២. ការងារអប់រំតាមសហគមន៍

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បានធ្វើការអប់រំផ្សព្វផ្សាយពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន មានមហាជនទៅទទួលសារសារអប់រំចំនួន **១៣០.០០៤** នាក់ ។

ក្នុងនោះ ការងារដែលអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានសហការអនុវត្តជាមួយ ៖

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ និងសហការី ចូលរួមជាអធិបតី និងធ្វើបទឧទ្ទេសនាមនៅក្នុងពិធីផ្សព្វផ្សាយអំពីគ្រោះថ្នាក់នៃគ្រឿងញៀន ដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៩-៣១ ខែមីនា ឆ្នាំ២០១៨ នៅស្រុកកងមាស ខេត្តកំពង់ចាម

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានជំរុញឱ្យក្រសួងស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្តនិងសមាគមពាក់ពន្ធ័មានសកម្មភាពអប់រំផ្សព្វផ្សាយស្តីពី បញ្ហាគ្រឿងញៀន នៅក្នុងឱកាសបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ កាលពីថ្ងៃទី១៤-១៦ ខែមេសា ឆ្នាំ២០១៨

- ថ្នាក់ដឹកនាំនិងមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមធ្វើបទបង្ហាញវគ្គផ្សព្វផ្សាយពីបញ្ហាគ្រឿងញៀន និងចរាចរណ៍ ដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា កាលពីថ្ងៃទី២៦-២៨ ខែមេសា ឆ្នាំ ២០១៨ នៅ ខេត្តព្រះសីហនុ

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. ចូលរួមក្នុងពិធីចែករំលែកចំណេះដឹងស្តីពីគ្រឿងញៀន ជូនដល់និស្សិតថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រនគរបាល ជំនាន់៧ កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ នៅបណ្ឌិត្យសភានគរបាលកម្ពុជា

- ក្រុមហ៊ុន HD&S Group Co.,LTD បានបញ្ជ្រាបខ្លឹមសារពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍ ដែលមានអ្នកចូលរួម ៦៨.៣៥០ នាក់

- ក្រសួងសាធារណការនិងដឹកជញ្ជូន ស្នើក្រុមហ៊ុនដឹកជញ្ជូនទាំងអស់ឱ្យណែនាំអ្នកបើកបរ សូមកុំឱ្យប្រើប្រាស់គ្រឿងញៀនខុសច្បាប់ និងស្នើឱ្យមានការបិទខិតប័ណ្ណផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមរថយន្ត ។

## ២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន

### ២.១. ការកាត់បន្ថយគ្រោះថ្នាក់

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមកិច្ចប្រជុំ Consensus Meeting IBBS among PWU/PWIDs, 2017 និងការប៉ាន់ប្រមាណរកចំនួនអ្នកប្រើប្រាស់គ្រឿងញៀន នៅប្រទេសកម្ពុជាឆ្នាំ២០១៧ ដែលរៀបចំដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើរស្បែក និងកាមរោគ នៃក្រសួងសុខាភិបាល កាលពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៨

- បន្តការគាំទ្រចំពោះអង្គការដៃគូ ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីកាត់បន្ថយការឆ្លងមេរោគអេសដ៍ និងរោគឆ្លងតាមឈាមផ្សេងៗទៀត

- បន្តផ្តល់សេវាព្យាបាលដោយឱសថជំនួសមេតាដូន ដល់អ្នកញៀនហេរ៉ូអ៊ីន (ពពួកអាភៀន) ។

### ២.២. ការព្យាបាល និងស្តារនីតសម្បទា

- បានជំរុញឱ្យគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ពង្រឹងឬបង្កើតគណៈកម្មការសម្របសម្រួលការព្យាបាលអ្នកញៀនគ្រឿងញៀន នៅតាមឃុំ-សង្កាត់ ដើម្បីជំរុញអ្នកប្រើប្រាស់ និងញៀនគ្រឿងញៀនឱ្យទៅទទួលយកការព្យាបាល នៅតាមមណ្ឌលសុខភាព មន្ទីរពេទ្យបង្អែក និងលើកកម្ពស់ការថែទាំបន្ត នៅតាមសហគមន៍

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងសហការី បានរៀបចំទទួលគណៈប្រតិភូនៃមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន របស់មហាក្សត្រីយានី នៃព្រះរាជណាចក្រថៃ មកធ្វើទស្សន

កិច្ច និងពិភាក្សាការងារព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន កាលពីថ្ងៃទី២៦-២៧ ខែ មីនា ឆ្នាំ២០១៨ នៅខេត្តកំពត ខេត្តព្រះសីហនុ និង រាជធានីភ្នំពេញ

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមនៅក្នុងសិក្ខាសាលា ស្តីពីការកសាងផែនការប្រតិបត្តិ និងប្រព័ន្ធរបាយការណ៍សុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន ដែលរៀបចំដោយក្រសួងសុខាភិបាល កាលពីថ្ងៃទី២៨-៣០ ខែមីនា ឆ្នាំ២០១៨ នៅខេត្តស្វាយរៀង

- បន្តដំណើរការសាងសង់អគាររដ្ឋបាល អគារមន្ទីរពេទ្យ អគារស្នាក់នៅ សាងសង់របង ឃ្លាំង បន្ទប់អគ្គិសនី បន្ទប់ចម្រោះទឹកស្អាត មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

- បានស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្តជួយផ្សព្វផ្សាយ និងបញ្ជូននូវបញ្ជីសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនឆ្នាំ២០១៧ ទៅដល់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់

- បានស្នើសុំទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជួយផ្សព្វផ្សាយ និងបញ្ជូននូវបញ្ជីសេវាសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀនឆ្នាំ២០១៧ ទៅដល់ព្រះរាជអាជ្ញារាជធានី-ខេត្ត ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់

### ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

- អគ្គលេខាធិការ អ.ជ.ប.គ.ញ. បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកឧក្រិដ្ឋកម្ម និងគ្រឿងញៀន (UNODC) សម្រាប់ជំនួយគម្រោងពាក់ព័ន្ធនឹងកម្មវិធីត្រួតពិនិត្យកុងតឺន័រតាមផ្លូវសមុទ្រ និងកម្មវិធីត្រួតពិនិត្យកុងតឺន័រតាមផ្លូវអាកាស កាលពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមកិច្ចប្រជុំជាមួយក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ (DBG) ដែលរៀបចំដោយធនាគារជាតិនៃកម្ពុជា កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញភូគីត្រា

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនតាមមេរៀនក្នុងប្រព័ន្ធកុំព្យូទ័រ (CBT) កាលពីថ្ងៃទី ០២-០៦ ខែមេសា ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលមានអ្នកចូលរួម ១២នាក់

- បានចាត់មន្ត្រី ២រូប ទៅបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តន៍ច្បាប់គ្រឿងញៀន តាមប្រព័ន្ធអេឡិចត្រូនិច (e-Learning) នាថ្ងៃទី២៤-២៩ ខែមេសា ឆ្នាំ២០១៨ នៅខេត្តកោះកុង ដែលមានអ្នកចូលរួម ២៦នាក់

- ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមត្រួតពិនិត្យ និងបើកកញ្ចប់វត្ថុតាងគ្រឿងញៀនដែលបានរឹបអូសនិងបំផ្លាញចោលតាមអំណាចសាលក្រម សាលដីកា និងដីកាសម្រេច កាលពីថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០១៨ នៅសាលាដំបូងខេត្តព្រះសីហនុ ។

### ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

- បទល្មើសគ្រឿងញៀនសរុប **៥៣៥ ករណី** (រួមទាំងបទល្មើសប្រើប្រាស់) ប្រៀបធៀបខែមីនាមាន **៥៥២ ករណី** មានការថយចុះ ១៧ករណី ស្មើនឹង ៣.០៧% ។

- **ជនសង្ស័យឃាត់ខ្លួន ១.០១៧នាក់ ស្រី ៩៤នាក់** (រួមទាំងជនប្រើប្រាស់) ប្រៀបធៀបខែមីនាមាន **១.១០២នាក់** មានការថយចុះ ៨៥នាក់ ស្មើនឹង ៧.៧១% ។

**ជនសង្ស័យទាំងអស់មាន ៧ សញ្ជាតិគឺ :** ខ្មែរ ៩៩៧នាក់ (ស្រី ៩៨នាក់),វៀតណាម ១៤ នាក់ (ស្រី ៤ នាក់), ថៃ ១នាក់, តៃវ៉ាន់ ២នាក់, អូស្ត្រាលី ១នាក់, បារាំង ១នាក់ និងអង់គ្លេស ១នាក់ ត្រូវបានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

**ក្នុងចំនួនបទល្មើសគ្រឿងញៀនខាងលើ ៖**

- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចនគរបាល ៤៥៤ ករណី** ឃាត់ខ្លួនជនសង្ស័យ **៩៣៨ នាក់** (ស្រី ៦៤នាក់)
- បទល្មើសគ្រឿងញៀន បង្ក្រាបដោយ **សមត្ថកិច្ចកងរាជអាវុធហត្ថ ៨១ករណី** ឃាត់ខ្លួនជនសង្ស័យ **១៧៩ នាក់** (ស្រី ៣០នាក់)

- **វត្ថុតាងគ្រឿងញៀនចាប់យក :** មេតំហ្វេតាមីនក្រាមម្សៅ(ICE) ១៦គ.ក្រ ២៤០ក្រាម ២០០មិល្លីក្រាម, មេតំហ្វេតាមីនគ្រាប់(WY) ២៨៣ក្រាម ៧០០មិល្លីក្រាម, អ៊ិចស្តាស៊ី ២៣២ក្រោម, ៣២០មិល្លីក្រោម, ហេរ៉ូអ៊ីន ២១៧ក្រាម ៨៣០មិល្លីក្រាម, កូកាអ៊ីន ១៦គ.ក្រ ៩២២ក្រាម, ៩០០មិល្លីក្រាម, កេតាមីន ១៥០ក្រាម,៣២០មិល្លីក្រាម, ដើមកញ្ឆា ១៦,៩១៥ ដើម ។

**(មេតំហ្វេតាមីន ICE និង WY សរុបរួម ៣៩គ.ក្រ ៨៨១ ក្រាម ៨០០ មិល្លីក្រាម)**

- **ទ្រព្យសម្បត្តិសំខាន់ៗ** ចាប់យកក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន រួមមាន រថយន្ត ៦ គ្រឿង, ម៉ូតូ ១៥៨ គ្រឿង, ទូរស័ព្ទ ៤៣៦ គ្រឿង, ជញ្ជីង ៣១ គ្រឿង, ប្រាក់កម្ពុជា ៦.៥០២.៨០០ រៀល, ប្រាក់ថៃ ៣.១០០បាត, ប្រាក់អាមេរិក ៨៥៤ ដុល្លារ, ប្រាក់វៀតណាម ៩,៤៥០.០០ ដុង
- **ជនសង្ស័យចាប់តាមដីកា** មាន ២១ ដីកា ចាប់បានជនសង្ស័យ ២០នាក់ (ស្រី១នាក់) ។

## ៣.៣. លទ្ធផលកោសលវិច្ច័យលើសំណាកសង្ស័យជាគ្រឿងញៀន

- សំណាកសង្ស័យជាគ្រឿងញៀន ដែលបានធ្វើកោសលវិច័យ ក្នុងខែមេសា ឆ្នាំ២០១៨ មាន **២២០ ករណី** ស្មើនឹង **២៣០ សំណាក** ក្នុងនោះ ៖

- **សំណាកវិជ្ជមានសារធាតុញៀន** មាន **២២០ ករណី = ២៣០ សំណាក** (៩៦,៦២%) គឺ :
  - មេតំហ្វេតាមីនគ្រាប់ (WY) ០៨សំណាក = ៣,៣៦%
  - មេតំហ្វេតាមីនក្រាមម្សៅ (ICE) ២០៥សំណាក = ៨៦,១៣%
  - កេតាមីន ០៤សំណាក = ១,៦៨%
  - កូកាអ៊ីន ០១សំណាក = ០,៤២%
  - MDMA ១១សំណាក = ៤,៦២%
  - កញ្ឆា ០៣សំណាក = ១,១៤%
- **សំណាកអវិជ្ជមានសារធាតុញៀន ០០ ករណី = ០៨សំណាក** (៣,៣៦%) ។

### ៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានចូលរួមសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រួតពិនិត្យសារជាតុញៀន ក្នុងតារាងទី២ និងទី៣ និងសារជាតុគីមីផ្សំក្នុងរាងទី៤ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ក្នុងខែ មេសា ឆ្នាំ២០១៨នេះ សរុបមាន **១.១០១.១៥០** គ.ក្រ ក្នុងនោះ ៖

  - ផ្ដល់អាជ្ញាបណ្ណ័និងលិខិតបញ្ជាក់មុខសញ្ញាស្តង់ដាប្រើប្រាស់សារជាតុគីមី ដោយក្រសួងឧស្សាហ-កម្ម និងសិប្បកម្ម មាន ១០៦.៣១០០ គ.ក្រ
  - ចេញអាជ្ញាប័ណ្ណ ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មាន ៣៨០.០០ គ.ក្រ
  - នាំចូល ដោយក្រសួងសុខាភិបាល មាន ៥០ គ.ក្រ ។

- អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានរៀបចំកិច្ចប្រជុំក្រុមលេខា នៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារជាតុគីមីផ្សំ ពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៨ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ។

### ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. និងសហការី ៥រូប ចូលរួមសិក្ខាសាលា ស្ដីពីការរៀបចំផែនការមេ៥ឆ្នាំ (២០១៩-២០២៣) នៃគម្រោងសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ (ONCB) កាលពីថ្ងៃទី០៨-១២ ខែមេសា ឆ្នាំ២០១៨ នៅខេត្តឈៀងម៉ៃ ប្រទេសថៃ ។

### ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ២រូប ចូលរួមសិក្ខាសាលាអាស៊ានស្ដីពីការវិភាគផ្លូវចរាចរគ្រឿងញៀន និងសារជាតុគីមីផ្សំតាមដងទន្លេមេគង្គ ដែលរៀបចំដោយអង្គការ UNODC កាលពីថ្ងៃទី០២-៣ ខែមេសា ឆ្នាំ២០១៨ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម

- បានចាត់មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ០៥ រូប ទៅចូលរួមវគ្គបណ្ដុះបណ្ដាលសិក្ខាសាលាជនបង្គោលថ្នាក់តំបន់ស្ដីពី ឧក្រិដ្ឋកម្មឆ្លងដែន គ្រឿងញៀន សារជាតុគីមីផ្សំ និងមន្ទីរពិសោធន៍ផលិតគ្រឿងញៀនលួចលាក់ ដែលរៀបចំដោយអង្គការ UNODC ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១៨ នៅខេត្តដាណាំង ប្រទេសវៀតណាម ។

### ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- ចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ១រូប ចូលរួមនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិ លើសេចក្ដីព្រាងរបាយការណ៍ជាតិគួបលើកទី៤ ទី៥ និងទី៦ ស្ដីពីការអនុវត្តសិទ្ធិកុមារ ដលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ កាលពីថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ នៅសណ្ឋាគារកាំបូឌីយ៉ាណា
- បន្តជំរុញការអនុវត្តសកម្មភាពនៃផែនការភូមិ ស គ្មានគ្រឿងញៀន
- បន្តរៀបចំខ្លឹមសារសេចក្តីព្រាងទាក់ទងមាត្រាមួយចំនួន ដែលបានចែងនៅក្នុងច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ។

## IV. ផែនការសកម្មភាពអនុវត្តទិសដៅត្រួតពិនិត្យគ្រឿងញៀន ខែឧសភា ឆ្នាំ២០១៨

ដើម្បីអនុវត្តបន្តឱ្យមានប្រសិទ្ធភាព នូវផែនការជាតិស្ដីពីការត្រួតពិនិត្យគ្រឿងញៀនឆ្នាំ២០១៨ ផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ (ឆ្នាំ២០១៨) អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. បានដាក់ចេញនូវផែនការសកម្មភាពអនុវត្តទិសដៅការងារ សម្រាប់**ខែឧសភា ឆ្នាំ ២០១៨** ដូចខាងក្រោម ៖

**១.	ការអប់រំ ផ្សព្វផ្សាយ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន**

១.១. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមជាវាគ្មិន (Guest Speaker) និងធ្វើបទឧទ្ទេសនាមស្តីពីការផ្សព្វផ្សាយពីផលប៉ះពាល់នៃការសេពគ្រឿងញៀន ដើម្បីបញ្ជ្រាបការយល់ដឹងទូទៅពីគ្រឿងញៀន ដែលរៀបចំដោយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ នៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ។

១.២. មន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ១រូប ត្រៀមចូលរួមធ្វើបទបង្ហាញស្តីពីការចូលរួមទាំងអស់គ្នាដើម្បីឱ្យជីវិត និងសហគមន៍យើងគ្មានគ្រឿងញៀន ដែលរៀបចំដោយក្រសួងធម្មការ និងសាសនា កាលពីថ្ងៃទី២៨ ខែ មេសា ឆ្នាំ ២០១៨ នៅសណ្ឋាគារពមករា ខេត្តកំពង់ចាម

១.៣. បន្តកិច្ចសហការជាមួយក្រសួងទេសចរណ៍, ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីផ្សព្វផ្សាយច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន, សភាពការណ៍គ្រឿងញៀន, ចំណេះដឹងទូទៅពីគ្រឿងញៀន, ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមតំបន់ទេសចរណ៍របស់រាជធានី-ខេត្ត តាមគ្រឹះស្ថានសិក្សា និងនៅតាមបណ្តារោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងក្នុងរាជធានីភ្នំពេញ ។

១.៤. ត្រៀមចូលរួមផ្តល់កិច្ចសម្ភាសន៍ ក្រោមប្រធានបទស្តីពីលទ្ធផលនៃការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ របស់រាជរដ្ឋាភិបាល នៅស្ថានីយទូរទស្សន៍ហង្សមាស ។

១.៥. បន្តសហការជាមួយស្ថានីយទូរទស្សន៍ ស៊ី.អិន.ស៊ី. អញ្ជើញតំណាងក្រសួងពាណិជ្ជកម្ម ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលថ្ងៃត្រង់ និងតំណាងក្រសួងការពារជាតិ ចូលរួមផ្តល់កិច្ចសម្ភាសន៍ក្នុងកម្មវិធីព័ត៌មានពេលល្ងាច ក្រោមប្រធានបទ ការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៣។

១.៦. បន្តសហការជាមួយស្ថានីយទូរទស្សន៍បាយ័ន ហង្សមាស និងNICETV ដើម្បីធ្វើការផ្សព្វផ្សាយពីការងារដែលទាក់ទងនឹងបញ្ហាគ្រឿងញៀន។

១.៧. បន្តសហការជាមួយក្រុមហ៊ុន HD &S Group Co.,LTD បញ្ជ្រាបខ្លឹមសារអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីប្រគំតន្ត្រីទេសចរណ៍គ្មានគ្រឿងញៀន ។

១.៨. បន្តរៀបចំកម្មវិធីប្រឡងតែងកំណាព្យ និងគូរគំនូរប្រឆាំងគ្រឿងញៀន ។

១.៩. បន្តចលនាឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ក្នុងការងារអប់រំផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.១០. បន្តបោះពុម្ពខិត្តប័ណ្ណអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន សម្រាប់ផ្សព្វផ្សាយអប់រំទៅលើក្រុមគោលដៅជាសិស្សានុសិស្ស ។

១.១១. បន្តជម្រុញនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ការងារផ្សព្វផ្សាយអប់រំជាមួយវិស័យឯកជន និងក្រុមហ៊ុន ។

១.១២. ត្រៀមរៀបចំទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននាថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។

**២. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ បំណិនជីវិត ការធ្វើសមាហរណកម្ម និងចាកចេញពីគ្រឿងញៀន**

២.១. ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ត្រៀមចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាយោបល់មជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាប្រឆាំងមេអេគអេដស៍អាស៊ីអាគ្នេយ៍ (SEA-HATTC) ដែលរៀបចំដោយមជ្ឈមណ្ឌលប្រព័ន្ធផ្ទេរបច្ចេកវិទ្យានៃការញៀន (ATTC) នៅខេត្តឈៀងម៉ៃ ប្រទេសថៃ ។

២.២. ចាត់បញ្ជូនមន្ត្រីសហការប្រមូលទិន្នន័យការអង្កេតរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ការប្រព្រឹត្តផ្លូវភេទ និងការប៉ាន់ប្រមាណរកចំនួនអ្នកប្រើប្រាស់គ្រឿងញៀននៅប្រទេសកម្ពុជាឆ្នាំ២០១៧ ។

២.៣. បន្តជំរុញសកម្មភាពផ្សព្វផ្សាយឱ្យកាន់តែសកម្ម ដើម្បីឱ្យអ្នករងគ្រោះដោយសារគ្រឿងញៀនបានដឹង និងទៅទទួលយកសេវាព្យាបាលនៅតាមមន្ទីរពេទ្យបង្អែក ឬមណ្ឌលសុខភាព ។

២.៤. បន្តការកែសម្រួលនិងពង្រឹងសមត្ថភាព គុណភាព នៃយន្តការគ្រប់គ្រងមណ្ឌលបណ្ដោះអាសន្នសម្រាប់អប់រំ បន្សាប ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

២.៥. បន្តដំណើរការសាងសង់មជ្ឈមណ្ឌលផ្តល់សេវាព្យាបាលដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ដល់អ្នកញៀនគ្រឿងញៀន នៅភូមិឫទ្ធី២ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ។

២.៦. បន្តជំរុញការរៀបចំសេវាព្យាបាល និងស្តារនីតិសម្បទាដល់អ្នកញៀនគ្រឿងញៀន ដែលជាទណ្ឌិតនៅតាមមណ្ឌលអប់រំកែប្រែ និងពន្ធនាគារ ។

២.៧. បន្តចលនា និងផ្តល់ការសម្របសម្រួលឱ្យមានការចូលរួមពីវិស័យឯកជន លើការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

**៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តន៍ច្បាប់**

៣.១. បន្តកិច្ចសហការជាមួយអង្គការ UNODC ដើម្បីរៀបចំបង្កើតការិយាល័យទំនាក់ទំនង (**BLO**) ថ្មី កម្ពុជា-វៀតណាម ចំនួន ២ នៅច្រកទ្វារព្រំដែនអន្តរជាតិអូយ៉ាដាវ (ខេត្តរតនគិរី) និងច្រកទ្វារព្រំដែនអន្តរជាតិព្រែកចាក (ខេត្តកំពត) ។

៣.២. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមកិច្ចប្រជុំការិយាល័យទំនាក់ទំនងព្រំដែនកម្ពុជា-ថៃ ដែលរៀបចំដោយក្រុមប្រឹក្សាត្រួតពិនិត្យគ្រឿងញៀនថៃ នៅខេត្តចាន់ថាបូរី ប្រទេសថៃ ។

៣.៣. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ. ចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពីការអនុវត្តគោលការណ៍ និងការត្រួតពិនិត្យឯកសារពាក់ព័ន្ធ សម្រាប់មន្ត្រីបម្រើការងារនៅតាមច្រកទ្វារព្រំដែន នៅសណ្ឋាគារ ហ៊ីម៉ាវ៉ារី រាជធានីភ្នំពេញ ។

៣.៤. ត្រៀមជួបពិភាក្សាការងារជាមួយសមាជិកដែលពាក់ព័ន្ធអំពីការអនុវត្តគម្រោង PATROL នៅតាមព្រំដែននៃច្រកទ្វារនីមួយៗ ។

៣.៥. បន្តបណ្តុះបណ្តាលមន្ត្រីអនុវត្តន៍ច្បាប់ស្តីពីគ្រឿងញៀន តាមមេរៀនក្នុងប្រព័ន្ធអេឡិចត្រូនិច (e-Learning) និងតាមប្រព័ន្ធកុំព្យូទ័រ (CBT) ។

៣.៦. ជំរុញការបង្កើតក្រុមការងារត្រួតពិនិត្យគ្រឿងញៀន តាមអាកាសយានដ្ឋានអន្តរជាតិ និងកំពង់ផែអន្តរជាតិ ។

**៤. ការត្រួតពិនិត្យសារធាតុគីមីផ្សំ**

៤.១. បន្តការចងក្រងព័ត៌មានពាក់ព័ន្ធនឹងសារធាតុញៀនថ្មី ដែលមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ ។

៤.២. បន្តចូលរួមជាមួយក្រសួងឧស្សាហកម្មនិងសិប្បកម្ម ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធនឹងទំនិញគ្រោះថ្នាក់។

៤.៣. បន្តរៀបចំកិច្ចប្រជុំក្រុមលេខានៃក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំឱ្យបានទៀងទាត់។

៤.៤. ត្រៀមរៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួងត្រួតពិនិត្យសារធាតុគីមីផ្សំ ។

**៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន**

៥.១. បន្តអនុវត្តផែនការសកម្មភាព ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី កម្ពុជា-ថៃ ឆ្នាំ២០១៧-២០១៨ ។

៥.២. បន្តអនុវត្តផែនការសកម្មភាពគម្រោងសុវត្ថិភាពទន្លេមេគង្គក្រោមសម្រាប់កម្ពុជា ថៃ ឡាវ រយៈពេល ២ឆ្នាំ (២០១៧ -២០១៨) ។

៥.៣. ត្រៀមចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ១ រូប ទៅចូលរួមកិច្ចប្រជុំ គណៈកម្មការចម្រុះកម្ពុជា-វៀតណាម )JC) លើកទី១៦ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ពីថ្ងៃទី១៦-១៨ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងហាណូយ ប្រទេសវៀតណាម ។

៥.៤. ត្រៀមទៅចូលរួមកិច្ចប្រជុំត្រីភាគី-ទ្វេភាគី កម្ពុជា-ឡាវ-វៀតណាម ដែលនឹងប្រារព្ធនៅប្រទេសឡាវ ។

**៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា**

៦.១. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣. ២រូប ចូលរួមក្នុងសន្និបាតថ្នាក់តំបន់អាស៊ាន សមកាលសេដ្ឋកិច្ច និងសន្តិសុខអាស៊ានឆ្នាំ២០២៥ (ការជួញដូរគ្រឿងញៀន) ដែលរៀបចំដោយអង្គការ UNODC នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.២. អគ្គលេខាធិការ អ.ជ.ប.គ.៣. និងសហការី ២រូប ត្រៀមចូលរួមកិច្ចប្រជុំគណៈកម្មាធិការមន្ត្រីជាន់ខ្ពស់បណ្តាប្រទេសសមាជិកហត្ថលេខីនៃ MOU ទន្លេមេគង្គ ដែលរៀបចំដោយគណៈកម្មាធិការកណ្តាលត្រួតពិនិត្យគ្រឿងញៀនមីយ៉ាន់ម៉ា (CCDAC) នៅទីក្រុងណៃពិដោរ សាធារណៈរដ្ឋសហភាពមីយ៉ាន់ម៉ា ។

៦.៣. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ១រូប ចូលរួមក្នុងសន្និសិទអាស៊ានស្តីពីកំណែទម្រង់ប្រព័ន្ធយុត្តិធម៌កុមារ ដែលរៀបចំដោយអង្គការ UNICEF ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៨ នៅទីក្រុងបាងកក ប្រទេសថៃ ។

៦.៤. ត្រៀមចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ១រូប និងសហការី ១០រូប ទៅចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាពិគ្រោះយោបល់របស់មជ្ឈមណ្ឌល Southeast Asia HIV-Addiction Technology Transfer Center )SEA-HATTC( និងវគ្គបណ្តុះបណ្តាល ពីថ្ងៃទី៨ ដល់ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៨ នៅខេត្ត ឈៀងម៉ៃ ប្រទេសថៃ ។

៦.៥. ត្រៀមចាត់បញ្ជូនមន្ត្រីអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ២រូប ត្រៀមសហការសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាលជនបង្គោល ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ពីថ្ងៃទី២១ ខែឧសភា ដល់ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១៨ នៅទីក្រុងភ្នំពេញ។

**៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ**

៧.១. ត្រៀមផ្សព្វផ្សាយ ព្រះរាជក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

៧.២. បន្តណែនាំឱ្យរាជធានី-ខេត្ត បង្កើតគណៈកម្មការសម្របសម្រួលសម្រាប់ការព្យាបាល និងស្តារនីតិសម្បទា នៅឃុំ-សង្កាត់ ដើម្បីគាំទ្រដល់មណ្ឌលសុខភាពសម្រាប់ការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ។

៧.៣. បន្តការចូលរួមអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី៣ ឆ្នាំ២០១៨ (០១ ខែមករា-៣១ ខែធ្នូ ឆ្នាំ២០១៨) ។

៧.៤. បន្តការរៀបចំការកែសម្រួលមាត្រាមួយចំនួន ពាក់ព័ន្ធនឹងការរឹបអូសទ្រព្យសម្បត្តិដែលជាផលបានមកពីបទល្មើសគ្រឿងញៀន ដែលមានចែងនៅក្នុងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

អគ្គលេខាធិការ

នាយឧត្តមសេនីយ៍ មាស-វិរិទ្ធ

**ចម្លងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ.
- ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.

" ដើម្បីជូនជ្រាប "

- ក្រសួង ស្ថាប័ន សមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីមុខការ "

- ឯកសារ-កាលប្បវត្តិ